# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ ៩..១..៩..... ប្រក.សក-សហវ.ចមព

រាជធានីភ្នំពេញ,ថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០០៩

លិខិតចូល
ថ្ងៃទី១៩....ខែតុលា..ឆ្នាំ2009

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់តម្លៃលេខចុះបញ្ជីរថយន្តធុនទេសចរណ៍

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- តាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បច្ចុប្បន្ន

## **ស ម្រេ ច**

**ប្រការ ១ :**

ត្រូវបានកំណត់លេខចុះបញ្ជីរថយន្តធុនទេសចរណ៍ចំនួនពីរប្រភេទ សម្រាប់ដាក់លក់ និងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដូចខាងក្រោម ÷

**ក- លេខចុះបញ្ជីរថយន្តប្រភេទទី ១**

- លទ្ធផលខ្ទង់រាយនៃផលបូកលេខទាំងបួនខ្ទង់ ជាលេខ ៦ ឬលេខ ៧ ឬលេខ ៨ ឬលេខ ៩
- មានលេខគូ ស្ថិតនៅខ្ទង់ជាប់គ្នាពីរ
- មានលេខបីខ្ទង់ ជាលេខដូចគ្នា និងស្ថិតនៅខ្ទង់ជាប់គ្នា។

**ខ- លេខចុះបញ្ជីរថយន្តប្រភេទទី ២**

- មានលេខទាំងបួនខ្ទង់ ជាលេខដូចគ្នា
- មានលេខ ១៦៨ ស្ថិតនៅខាងចុង
- មានលេខទាំងបួនខ្ទង់ ជាលេខរៀងគ្នាតាមលំដាប់ឡើងចាប់ពីខ្ទង់ទី ១ រហូតដល់ខ្ទង់ទី ៤។

**ប្រការ ២ :**

លេខចុះបញ្ជីរថយន្តប្រភេទទី ១ និងប្រភេទទី ២ ខាងលើ ត្រូវបានបែងចែកជាបីតំបន់ ដូចខាងក្រោម ÷

- **តំបន់ទី ១ :** លេខរថយន្តដែលត្រូវចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- **តំបន់ទី ២ :** លេខរថយន្តដែលត្រូវចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តព្រះសីហនុ
- **តំបន់ទី ៣ :** លេខរថយន្តដែលត្រូវចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកោះកុង ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តបន្ទាយមានជ័យ ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន និងខេត្តកែប។

**ប្រការ ៣ :**

លេខចុះបញ្ជីរថយន្តធុនទេសចរណ៍ប្រភេទទី ១ ត្រូវបានកំណត់តម្លៃសម្រាប់លក់ និងលេខចុះបញ្ជីរថយន្តធុនទេសចរណ៍ប្រភេទទី ២ ត្រូវបានកំណត់តម្លៃជាមូលដ្ឋានសម្រាប់ដាក់ឱ្យដេញថ្លៃជាសាធារណៈ ដូចតទៅ ÷

**ក- តម្លៃលក់លេខចុះបញ្ជីរថយន្តធុនទេសចរណ៍ប្រភេទទី ១**

តម្លៃគិតជាដុល្លារអាមេរិក

| ល.រ | បរិយាយប្រភេទលេខរថយន្ត | តម្លៃលក់ក្នុងមួយលេខ | | |
|---|---|---|---|---|
| | | តំបន់ទី ១ | តំបន់ទី ២ | តំបន់ទី ៣ |
| ១ | **លទ្ធផលខ្ទង់រាយនៃផលបូកលេខទាំងបួនខ្ទង់ :** | | | |
| | - ជាលេខ ៦ | 5 | | |
| | - ជាលេខ ៧ | 15 | 5 | 5 |
| | - ជាលេខ ៨ | 15 | 10 | 5 |
| | - ជាលេខ ៩ | 20 | 15 | 10 |
| ២ | **មានលេខគូ ស្ថិតនៅខ្ទង់ជាប់គ្នាពីរៗ :**<br>1122 - 1133 - 1144 - 1155 - 1166 - 1177 - 1188 - 1199<br>2211 - 2233 - 2244 - 2255 - 2266 - 2277 - 2288 - 2299<br>3311 - 3322 - 3344 - 3355 - 3366 - 3377 - 3388 - 3399<br>4411 - 4422 - 4433 - 4455 - 4466 - 4477 - 4488 - 4499<br>5511 - 5522 - 5533 - 5544 - 5566 - 5577 - 5588 - 5599<br>6611 - 6622 - 6633 - 6644 - 6655 - 6677 - 6688 - 6699<br>7711 - 7722 - 7733 - 7744 - 7755 - 7766 - 7788 - 7799<br>8811 - 88222 - 8833 - 8844 - 8855 - 8866 - 8877 - 8899<br>9911 - 9922 - 9933 - 9944 - 9955 - 9966 - 9977 - 9988 | 300 | 150 | 100 |
| ៣ | **មានលេខបីខ្ទង់ ជាលេខដូចគ្នា និងស្ថិតនៅខ្ទង់ជាប់គ្នា**<br>ក- មានលេខបីខ្ទង់ ជាលេខដូចគ្នា និងស្ថិតនៅខ្ទង់ជាប់គ្នាបែកខាងដើម :<br>1112 - 1113 - 1114 - 1115 - 1116 - 1117 - 1118 - 1119<br>2221 - 2223 - 2224 - 2225 - 2226 - 2227 - 2228 - 2229<br>3331 - 3332 - 3334 - 3335 - 3336 - 3337 - 3338 - 3339<br>4441 - 4442 - 4443 - 4445 - 4446 - 4447 - 4448 - 4449<br>5551 - 5552 - 5553 - 5554 - 5556 - 5557 - 5558 - 5559<br>6661 - 6662 - 6663 - 6664 - 6665 - 6667 - 6668 - 6669 | 200 | 100 | 80 |

| | | | | |
|---|---|---|---|---|
| | 7771 - 7772 - 7773 - 7774 - 7775 - 7776 - 7778 - 7779<br>8881 - 8882 - 8883 - 8884 - 8885 - 8886 - 8887 - 8889<br>9991 - 9992 - 9993 - 9994 - 9995 - 9996 - 9997 - 9998 | 200 | 100 | 80 |
| | ខ- មានលេខបីខ្ទង់ ជាលេខដូចគ្នា និងស្ថិតនៅខ្ទង់ជាប់គ្នាប៉ែកខាងចុង :<br>1222 - 1333 - 1444 - 1555 - 1666 - 1777 - 1888 - 1999<br>2111 - 2333 - 2444 - 2555 - 2666 - 2777 - 2888 - 2999<br>3111 - 3222 - 3444 - 3555 - 3666 - 3777 - 3888 - 3999<br>4111 - 4222 - 4333 - 4555 - 4666 - 4777 - 4888 - 4999<br>5111 - 5222 - 5333 - 5444 - 5666 - 5777 - 5888 - 5999<br>6111 - 6222 - 6333 - 6444 - 6555 - 6777 - 6888 - 6999<br>7111 - 7222 - 7333 - 7444 - 7555 - 7666 - 7888 - 7999<br>8111 - 8222 - 8333 - 8444 - 8555 - 8666 - 8777 - 8999<br>9111 - 9222 - 9333 - 9444 - 9555 - 9666 - 9777 - 9888 | 400 | 150 | 100 |

**ខ- តម្លៃមូលដ្ឋានលេខចុះបញ្ជីរថយន្តធុនទេសចរណ៍ប្រភេទទី ២ សម្រាប់ដាក់ឱ្យដេញថ្លៃជាសាធារណៈ**

តម្លៃគិតជាដុល្លារអាមេរិក

| ល.រ | បរិយាយប្រភេទលេខរថយន្ត | តម្លៃមូលដ្ឋានក្នុងមួយលេខ | | |
|---|---|---|---|---|
| | | តំបន់ទី ១ | តំបន់ទី ២ | តំបន់ទី ៣ |
| ១ | **លេខទាំងបួនខ្ទង់ ជាលេខដូចគ្នា :**<br>1111 - 2222 - 3333 - 4444 - 5555 - 6666 - 7777 - 8888 - 9999 | 1 000 | 500 | 200 |
| ២ | **មានលេខ ១៦៨ ស្ថិតនៅបីខ្ទង់ខាងចុង :**<br>0168 - 1168 - 2168 - 3168 - 4168 - 5168 - 6168 - 7168 - 8168 - 9168 | 800 | 500 | 200 |
| ៣ | **លេខទាំងបួនខ្ទង់ ជាលេខរៀងគ្នាតាមលំដាប់ឡើង :**<br>0123 - 1234 - 2345 - 3456 - 4567 - 5678 - 6789 | 600 | 300 | 100 |

**ប្រការ ៤:**

ការចាត់ចែងលក់ ការដាក់ឱ្យដេញថ្លៃលេខចុះបញ្ជីរថយន្ត និងការគ្រប់គ្រងប្រាក់ចំណូល ត្រូវដឹកនាំចាត់ចែងដោយគណៈកម្មការចម្រុះ ដែលមានសមាសភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៥ :**

លេខចុះបញ្ជីរថយន្តដែលដាក់ឱ្យដេញថ្លៃជាសាធារណៈ ត្រូវអនុវត្តតាមវិធីសាស្ត្រដេញថ្លៃឡើង។

**ប្រការ ៦ :**

បុគ្គលដែលបានទិញ ឬដេញថ្លៃបានលេខចុះបញ្ជីរថយន្ត ពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត បុគ្គលនោះត្រូវបានទទួលស្គាល់ថាជាម្ចាស់កម្មសិទ្ធិនៃលេខចុះបញ្ជីនោះ ដែលមានសិទ្ធិលក់បន្ត ធ្វើអំណោយ ចែកជាកេរមត៌ក និងអាចផ្លាស់ប្តូរពីរថយន្តមួយទៅរថយន្តមួយទៀតបាន។

សិទ្ធិខាងលើនេះ មានព្រំដែនកំណត់ត្រឹមរាជធានី ខេត្ត ដែលម្ចាស់រថយន្តមានអាសយដ្ឋានអចិន្ត្រៃយ៍តែប៉ុណ្ណោះ។ ក្នុងករណី ម្ចាស់កម្មសិទ្ធិផ្លាស់ប្តូរទីលំនៅអចិន្ត្រៃយ៍ទៅរស់នៅរាជធានី ឬខេត្ត ផ្សេងទៀតនោះ សិទ្ធិលើលេខចុះបញ្ជីដែលរៀបរាប់ខាងលើនេះ ត្រូវទុកជាមោឃៈ។

នៅរាល់ការលក់បន្ត ធ្វើអំណោយ ចែកជាកេរមត៌ក និងការផ្លាស់ប្តូរពីរថយន្តមួយទៅរថយន្តមួយទៀត ម្ចាស់រថយន្តថ្មី និងម្ចាស់រថយន្តចាស់ ត្រូវទៅដាក់ពាក្យសុំធ្វើការចុះបញ្ជីសាជាថ្មីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត។

**ប្រការ ៧ :**

នៅពេលបានទទួលប្រាក់ចំណូលពីការលក់ ឬពីការដេញថ្លៃលេខចុះបញ្ជីរថយន្ត មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវចេញបង្កាន់ដៃបង់ប្រាក់មួយសន្លឹកជូនអតិថិជន។ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៨ :**

ក្នុងករណីការដេញថ្លៃលេខចុះបញ្ជីរថយន្ត ប្រព្រឹត្តទៅបានលើសពីតម្លៃមូលដ្ឋានដែលបានកំណត់នៅក្នុងប្រការ ៣ នៃប្រកាសអន្តរក្រសួងនេះ ត្រូវធ្វើការបែងចែកដូចតទៅ :

- ទឹកប្រាក់ចំនួន ៤៥% នៃចំនួនទឹកប្រាក់ដែលលើសនោះ សម្រាប់ជាប្រាក់រង្វាន់លើកទឹកចិត្តផ្តល់ជូនគណៈកម្មការចម្រុះ ដែលមានចែងក្នុងប្រការ ៤ នៃប្រកាសអន្តរក្រសួងនេះ
- ទឹកប្រាក់ចំនួន ៥% នៃចំនួនទឹកប្រាក់ដែលលើសនោះ សម្រាប់អភិវឌ្ឍអគ្គនាយកដ្ឋានដឹកជញ្ជូន
- ទឹកប្រាក់ចំនួន ៥០% នៃចំនួនទឹកប្រាក់ដែលលើសនោះ សម្រាប់បង់ចំណូលចូលថវិការដ្ឋ។

**ប្រការ ៩ :**

ប្រាក់ចំណូលដែលប្រមូលបានពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីរថយន្ត មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវបង់ចូលថវិការដ្ឋ ដោយកត់ត្រាជាចំណូលរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅក្នុងជំពូក ៧៣ គណនី ៧៣២ អនុគណនី ៧៣២៥ " ផលពីការលក់ស្លាកលេខ " ។

**ប្រការ ១០ :**

ប្រកាសអន្តរក្រសួងនេះ ពុំមានអានុភាពប្រតិសកម្មចំពោះសិទ្ធិ និងការទទួលខុសត្រូវ សម្រាប់លេខចុះបញ្ជីរថយន្ត ដែលបានប្រើប្រាស់ជាផ្លូវការ មុនពេលប្រកាសអន្តរក្រសួងនេះចូលជាធរមានឡើយ ។

**ប្រការ ១១ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២ :**

ឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ត្រាំ អ៊ីវទិក

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត និងសាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ